អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ប្លេប៊ិយសម្ភាសន៍ នរោត្តម-សីហនុ

ដោយ Debra Weiner

បោះពុម្ពផ្សាយថ្ងៃទី១ ឧសភា ១៩៨៧

ប្រែសម្រួលដោយ លី-ឌៀប

PLAYBOY



«យើងជាខ្មែរ ជឿការចាប់កំណើតជាថ្មី ។ បើប្រសិនណាខ្ញុំកើតមកជាមនុស្ស ខ្ញុំសូមបន់ស្រន់តែម៉្យាងគត់ ៖ គឺខ្ញុំមិនចង់ធ្វើជាស្ដេច ឬជានាយករដ្ឋមន្ត្រីទេ!»

ប្លេប៊ិយ ៖ សម្ដេច, ព្រះអង្គធ្លាប់ធ្វើជាព្រះមហាក្សត្រ, ជាប្រមុខរដ្ឋ ហើយក្នុងពេលឥឡូវនេះធ្វើជាប្រធាននិរទេសរបស់ខ្មែរ ប៉ុន្ដែអនុញ្ញាតឲ្យយើងចាប់ផ្ដើមពីរឿងផ្ទាល់ខ្លួនសិន ។ ព្រះអង្គមានជីវិតរស់នៅយ៉ាងហ៊ឺហា ផ្ដល់ថ្វាយឲ្យដោយរដ្ឋាភិបាលចិន និងកូរ៉េខាងជើង ។ តើព្រះអង្គមានអារម្មណ៍មិនស្រណុកស្រួលបែបណាមួយដែរឬទេ បើគិតទៅដល់លក្ខណៈនៃការរស់នៅរបស់ព្រះអង្គក្នុងស្រុកខ្មែរ និងនៅក្នុងជំរំជនភៀសខ្លួន ?

នរោត្តម-សីហនុ ៖ ជនក្រីក្រ, ប្រជារាស្ដ្រតូចតាចរបស់ខ្មែរ គេពុំដែលរិះគន់ខ្ញុំទេ ។ ពួកគេមិនដែលតូចចិត្តនឹងអ្វីឡើយ, ពី-ព្រោះពួកគេមានអារម្មណ៍ថា ពួកគេដូចគ្នានឹងខ្ញុំដែរ។ មានពួកបញ្ញវ័ន្តជនភៀសខ្លួនខ្លះនិយាយថា ស្ដេចគិតតែពីរាំវែក ស្រែកច្រៀង និងលេងភ្លេង នៅក្នុងពេលដែលប្រជារាស្ដ្រយើងមានទុក្ខ ។ ក៏ប៉ុន្ដែនៅក្នុងពេលជាមួយគ្នា ប្រជារាស្ដ្រក៏រាំវែកដែរ ។ ខ្ញុំមានរូបថតអំពីប្រជារាស្ដ្រខ្មែរជាច្រើនសប្បាយរីករាយក្នុងជីវិតជាធម្មតា ។ មានឬក្រ, យើងចូលចិត្តរាំវែក, ចូលចិត្តភ្លេងភ្លាត់ និងការសំដែងសិល្បៈផ្សេងៗ ។ នេះគឺជារបៀបរស់នៅរបស់យើងទៅហើយ ។ ទោះនៅក្នុងជំរំជនភៀសខ្លួន ពួកគេមានវង់ភ្លេងបុរាណ និងវង់ភ្លេងទំនើប ។ ពួកគេមានក្រុមរបាំ បាល់ទ្បេ ។ ពួកគេរាំ, ពួកគេស៊ីផឹក ។ របៀបខ្មែររស់នៅគឺអញ្ចឹង ។ ហេតុដូច្នេះ ខ្ញុំមិនខ្វល់នឹងពួកមនុស្សដែលរិះគន់ខ្ញុំទាំងនោះទេ, ពីព្រោះខ្ញុំដឹងថាភាគច្រើនគេមិនរិះគន់ឡើយ ។ បើទោះបីខ្ញុំបោះបង់ការរាំវែក, សាំប៉ាញ, ម្ហូបអាហារល្អៗ, សំលៀកបំពាក់ល្អៗចោលយ៉ាងណាក៏ដោយ ខ្លួនខ្ញុំនៅតែមានបច្ចាមិត្រដដែលជាដដែលហ្នឹង ។

ប្លេប៊ិយ ៖ គេធ្លាប់ស្គាល់ព្រះអង្គថាជាស្ដេចប្លេប៊ិយ តើមែនដែរឬទេ ?

នរោត្តម-សីហនុ ៖ ប្លេប៊ិយឬ ? ខ្ញុំមិនដឹងទេ ។ ក៏ប៉ុន្ដែ...ចាចាស៎ ខ្ញុំមានរឿងផ្សេងព្រេងប្លែកៗជាច្រើន ។

ប្លេប៊ិយ ៖ ឧទាហរណ៍ដូចជា ?

នរោត្តម-សីហនុ ៖ ក្នុងឋានៈជាព្រះមហាក្សត្រ គេពុំអនុញ្ញាតឲ្យយើងមានមហេសីលើសពីម្នាក់ទេ តែគេអនុញ្ញាតឲ្យយើងមានស្រីស្នំរាប់រយ ។ កញ្ញាដឹងទេ... ជីតាទួតរបស់ខ្ញុំ, ព្រះបាទនរោត្តម, គាត់មាននៅក្នុងវាំងរបស់គាត់ស្រីប្រហែល៣០០... មិនមែនជាប្រពន្ធរបស់គាត់ទេ តែខ្ញុំសូមនិយាយថា ជាស្រីសំណប់ចិត្ត ។ ជីតារបស់ខ្ញុំ, ព្រះបាទមុនីវង្ស, គួរសមបន្តិច ។ គាត់មានតែ៦០ប៉ុណ្ណោះ ។ ឪពុករបស់ខ្ញុំក៏ជាប្លេប៊ិយដែរ ។ គាត់មានស្រីកំណាន់ជាផ្លូវការម្នាក់នៅក្នុងវាំងរបស់គាត់... ក៏ប៉ុន្ដែថ្ងៃមួយខ្ញុំបានរកឃើញសៀវភៅមួយ គាត់បានកត់ត្រាទុកអំពីរឿងផ្សេងព្រេងប្លែកៗរបស់គាត់ ។ គាត់មានស្រីដល់ទៅរាប់រយនាក់ឯណោះ ។ ក៏ប៉ុន្ដែខ្ញុំ ខ្ញុំបាត់បង់ពួកស្រីៗទាំងអស់នោះអស់ទៅហើយ នៅក្រោយពេលរដ្ឋប្រហារ ។
*(កកន ៖ ស្ដេចសីហនុបានហៅម្ដាយបង្កើតរបស់គាត់ជា «ស្រីកំណាន់ផ្លូវការ» របស់ឪពុកគាត់ ។ គិតទៅស្ដេចមានពូជខាងខូច តែមិនសូវសំបូណ៌សីលធម៌ប៉ុន្មានទេ) ។*

ប្លេប៊ិយ ៖ ឪពុកព្រះអង្គគាត់មានបញ្ជីរបស់គាត់ឬ ?

នរោត្តម-សីហនុ ៖ ចាស៎, (សើច) ប៉ុន្ដែខ្លួនខ្ញុំគ្មានបញ្ជីទេ ។ វាគួរឲ្យខ្មាស់អៀនខ្លាំងណាស់ ចំពោះពួកស្រីៗទាំងនោះ និងចំ-ពោះខ្លួនខ្ញុំ ។ ដូច្នេះខ្ញុំមិនកត់ត្រាអ្វីទុកទាំងអស់ ។ ក៏ប៉ុន្ដែឪពុកខ្ញុំគាត់អស្ចារ្យក្រៃលែង ។ គាត់មិនដែលសរសេរអំពីនយោបាយអ្វីទុកមួយបន្ទាត់ណាឡើយ ក្រៅអំពីរឿងស្នេហារបស់គាត់ ។ (សើច) ខ្ញុំចូលចិត្តលាក់ការសំដែងឫទ្ធិរបស់ខ្ញុំ... ខ្ញុំគ្មានមោទនភាពនៅក្នុងរឿងហ្នឹងទេ... ហើយសរសេរតែរឿងនយោបាយប៉ុណ្ណោះ ។ បើនិយាយទៅ ខ្ញុំមានប្រពន្ធជាផ្លូវការពីរ ។ ប្រពន្ធទី

១ត្រូវជាប្អូនជីដូនមួយរបស់ខ្ញុំ, មានខ្សែនរោត្តមដែរ, គាត់នៅជាមួយខ្ញុំចាប់ពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥២ ។ ក៏ប៉ុន្តែ... គាត់ប្រច័ណ្ឌខ្លាំងណាស់ ។ គាត់ហ្នឹងអស្ចារ្យតែម្តង ។ គាត់ដឹងថាប្តីរបស់គាត់នៅតែជាប្លេបិយដែរ... ហេតុដូច្នេះខ្ញុំពុំមានសេចក្តីសុខជាមួយគាត់ឡើយ ។ គាត់ជិនឆ្អន់ឆ្អែតចិត្តនឹងអាកប្បកិរិយាមិនស្មោះត្រង់របស់ខ្ញុំ ។ ដូច្នេះឥឡូវនេះ យើងក៏ដាច់ដោចគ្នា ហើយគាត់នៅឯក្រុងប៉ារីសឯណោះ។ក៏ប៉ុន្តែយើងនៅជាមិត្តល្អនឹងគ្នា។ប្រពន្ធថ្មីរបស់ខ្ញុំ...ចាប់ពីឆ្នាំ១៩៥២រហូតទៅដល់ណាណី... ខ្ញុំគិតថា គឺជា ម៉ូនិក-អ៊ីហ្សុី ។ ឪពុករបស់គាត់ជាជនជាតិអ៊ីតាលី ។
*(កកន ៖ ដូច្នេះម្តាយរបស់រណប្ញទ្ធិនិងបុប្ផាទេវី ហើយនិងម្តាយរបស់យុវនាថនិងចក្រពង្ស៍ពុំមែនជាប្រពន្ធពេញច្បាប់របស់ស្តេចសីហនុទេ ។ ម្ល៉ោះហើយបានជាអ្នកទាំងអស់នេះគ្មាននរណាអាចឡើងស្នងរាជ្យបន្តពីស្តេចសីហនុបាន) ។*

ប្លេបិយ ៖ តើព្រះអង្គនៅតែអត់ស្មោះត្រង់ដូច្នេះឬ ?

នរោត្តម-សីហនុ ៖ ពេលខ្ញុំដាក់រាជ្យកាលពីឆ្នាំ១៩៥៥,ខ្ញុំលែងមានស្នេហាលួចលាក់ទៀតហើយ។ក្នុងឋានៈជាព្រះមហាក្សត្រខ្ញុំអាចធ្វើជាប្លេបិយ ពីព្រោះខ្ញុំមានសម្បត្តិ និងទីពីរវាសមស្របទៅនឹងប្រពៃណីខ្មែរ ដែលស្តេចត្រូវមានស្រីស្នំច្រើន ។ ក៏ប៉ុន្តែជាមេដឹកនាំគណបក្សនយោបាយ, ខ្ញុំត្រូវតែចូលរួមបោះឆ្នោតរៀងរាល់បួនឆ្នាំម្តង ។ ខ្ញុំពុំអាចជាប្លេបិយបានទេ ។ បើពុំដូច្នោះទេ ពួកសត្រូវនយោបាយរបស់ខ្ញុំគេមុខតែនិយាយថា សីហនុមិននឹងធឹងឡើយ ។
*(កកន ៖ ផ្ទុយទៅវិញក្រោយពេលដាក់រាជ្យដើម្បីចុះមកប្រជែងអំណាចជាមួយរាស្ត្រ,ស្តេចសីហនុគាត់ក្លាយជា«ប្លេបិយ» ជាងកាលនៅជាស្តេចសោយរាជ្យទៅទៀត ។ គាត់បានក្លាយជាតួកុន ជាអ្នកចំរៀង ជាអ្នកលេងភ្លេង និងជាពិសេសគាត់ជាមេពូកែខាងធីងមោងអស្ចារ្យ ។ គាត់ចំណាប់ខាងកេះប្រពន្ធពួកមន្ត្រីឡេមឡឺម ដែលចង់បានបុណ្យស័ក្តិពីគាត់ យកទៅកំដរអារម្មណ៍នៅតាមដំណាក់នានា ។ ដំណាក់ចំការមននាពេលនោះ ស៊ីងក្លាយជា«វិមានប្លេបិយ»ទៅហើយ) ។*

ប្លេបិយ ៖ ដូច្នេះគ្មានទំនាក់ទំនងអ្វីលើសអំពីហ្នឹងទៀតទេឬ ?

នរោត្តម-សីហនុ ៖ អត់មានទេ, ក៏ប៉ុន្តែខ្ញុំមានប្រពន្ធដ៏ស្រស់បំព្រងម្នាក់ ។ ពិតប្រាកដណាស់ គាត់គឺជាស្រីម្នាក់ដ៏ស្រស់ខ្ពង់ជាងគេ ដែលខ្ញុំរកបាននៅក្នុងស្រុកខ្មែរ ។ (សើច) ហើយខ្ញុំបន្តចូលចិត្តភ្លេងភ្លាត់, ច្រៀងចំរៀង, ផទីសាំប៉ាញ, រាំវែក, ជិះសេះ, ភោជនិយដ្ឋានល្អៗ, រថយន្តកីឡា ។ (គាត់លើកក្រេបសាំប៉ាញរបស់គាត់) កញ្ញាដឹងទេ... រឿងបេះដូងនេះ គ្មានវិទ្យាសាស្ត្រ, គ្មានបច្ចេកទេសអ្វីទាំងអស់ ។

ប្លេបិយ ៖ តើពួកស្រីៗដែលរត់ទៅរកព្រះអង្គទាំងអស់នោះ គឺមកពីព្រះអង្គជាស្តេចមែនទេ ?

នរោត្តម-សីហនុ ៖ ខ្ញុំមិនអាចនិយាយអំពីស្រីទាំងអស់នោះទេ តែអំណាចទាក់ទាញ ពួកស្រីអស់នោះ ។ ទ្រព្យសម្បត្តិផងដែរ ក៏ប៉ុន្តែទោះបីបុរសនោះមិនស្ញូវសង្ហារក៏ដោយ... បើគាត់គួរជាទីចូលចិត្ត, ចេះនិយាយថៅរ៉ៅ និងមានបុកពាល្អ... ខ្ញុំគិតថាពួកស្រីៗចូលចិត្តគាត់ ។ រឿងនេះវាអាស្រ័យលើពួកស្រីៗទាំងនោះទេ ។ ខ្ញុំបានស្គាល់ស្រីខ្មែរខ្លះ ដែលបដិសេធរួមស្នេហ៍ជាមួយខ្ញុំ ។ ពួកគេនិយាយថា ពួកគេចូលចិត្ត (ហួចរបៀបហួសចិត្ត) ប្រុសៗណាដែល ខ្លាំងមានមាឌខ្ពស់ៗ ដូចជនអាហ្វ្រិកជាដើម ពីព្រោះពួកគេធីងមោងខ្លាំងៗ ។ ជនជាតិខ្មែរខ្លាំងដៃអស្ចារ្យមែន... តើកញ្ញាដឹងទេ ?

ប្លេបិយ ៖ អស្ចារ្យមែនឬ ?

នរោត្តម-សីហនុ ៖ ក៏ប៉ុន្តែ, កញ្ញាដឹងទេ, ខ្ញុំមិនយល់សោះអំពីពួកស្រីៗធីងមោងគ្នាឯង ។ ខ្ញុំគោរពសេរីភាពម្នាក់ៗ ប៉ុន្តែខ្ញុំមិនយល់ទាល់តែសោះអំពីពួកអ្នករួមភេទដូចគ្នា ។ ខ្ញុំមិនរិះគន់ពួកគេទេ ។ ខ្ញុំគោរពការរស់នៅរបស់ពួកគេ ។ តែខ្ញុំសូមបន់ព្រះឲ្យខ្ញុំជាមនុស្សធម្មតាដូចគេឯង ។ ខ្ញុំចូលចិត្តតែពួកស្រីៗប៉ុណ្ណោះ ។ យើងជាខ្មែរ, កញ្ញាដឹងទេ, យើងជឿលើការកើតឡើងវិញ ។ ដូច្នេះបើខ្ញុំបានវិលត្រឡប់មកពិភពនេះជាមនុស្ស, ខ្ញុំសូមបន់ស្រន់តែម៉្យាងគត់ ៖ គឺខ្ញុំមិនចង់ធ្វើជាស្តេចសោយរាជ្យទេ ។ ខ្ញុំមិនចង់ធ្វើជានាយករដ្ឋមន្ត្រីទេ ។ ខ្ញុំចង់ធ្វើជាមនុស្សធម្មតាៗ ដែលគ្មានអំណាច និងមិនយកភេទដូចគ្នា (សើច) នេះហើយគឺជាការបន់ស្រន់របស់ខ្ញុំសំរាប់ជាតិក្រោយ ។
*(កកន ៖ ចុះស្តេចកូនសីហមុនីរបស់ព្រះអង្គ តើកាលណាទៅទើបមានប្តីនឹងគេ ?) ។*

ប្លេបិយ ៖ សូមប្តូរសាច់រឿងម្តង... តើព្រះអង្គមានវីរបុរសរបស់ព្រះអង្គឬទេ ?

នរោត្តម-សីហនុ ៖ ខ្ញុំមានវីរបុរស... ដឺគ្រោលនៃប្រទេសបារាំង, ទីតូនៃប្រទេសយូហ្គោស្លាវី, ម៉ៅ-សេទុង និងជូ-អេនឡាយនៃប្រទេសចិន ។ ពួកគេជាអ្នកស្នេហាជាតិដ៏អស្ចារ្យ, ជាវីរបុរសនៃជាតិរបស់គាត់, ជាអ្នកតស៊ូដើម្បីសេរីភាព, ជាអ្នករំដោះទឹកដីរបស់ពួកគេ ។ ទី២, ពួកគេជាមនុស្សសុទ្ធសាធ ។ ពួកគេត្រូវប្រជារាស្ត្រស្រឡាញ់ ។ ដឺគ្រោលត្រូវគេរិះគន់ ពេលគាត់នៅរស់ ពីព្រោះបារាំងមិនចូលចិត្តស្រឡាញ់មេដឹកនាំណាដែលនៅរស់ទេ ។ ក៏ប៉ុន្តែការស្លាប់របស់ដឺគ្រោល បានត្រូវប្រជាជាតិបារាំងទាំងមូលស្រឡាញ់ ។ ហើយទីបី, ពីព្រោះពួកគេជាមិត្តដ៏ស្មោះស្ម័គ្រនឹងគ្នាណាស់ ។ ពួកគេយល់អំពីខ្ញុំ, យល់អំពីហេតុផលរបស់ខ្ញុំ ។ ពួកគេមិនចូលចិត្តពួកអ្នករិះគន់ណាដែលជឿថាខ្ញុំមិនទៀងត្រង់, ជាជនបែបម៉ាក្យាវ៉េល្លីយ៉ាងដូច្នេះជាដើម ។ ទេ... ពួកគេមិនដែលជឿបែបហ្នឹងទេ ។ ពិតមែនហើយ, ពួកគេគឺចំណោមជនដ៏អស្ចារ្យនៅក្នុងប្រវត្តិនៃមនុស្សជាតិនេះ ។

ប្លេបិយ ៖ តើព្រះអង្គមើលឃើញខ្លួនឯង ជាបុគ្គលតែម្នាក់គត់ ដែលអាចបង្រួបបង្រួមជាតិរបស់ព្រះអង្គដែរឬទេ ? មានជនខ្លះនិយាយថា ព្រះអង្គជាសេចក្តីសង្ឃឹមចុងក្រោយរបស់ខ្មែរ ។

នរោត្តម-សីហនុ ៖ កញ្ញាដឹងទេ... ខ្ញុំមិនចង់ធ្វើជាបុគ្គលអួតអាងថាខ្លួនដាច់គេនោះទេ, ក៏ប៉ុន្តែខ្ញុំប្រាកដណាស់ បើគ្មានខ្ញុំវៀតណាមនឹងបានអ្វីៗសព្វយ៉ាងឬទេ ។ ខ្ញុំពុំឃើញមាននរណាម្នាក់អាចជំនួសខ្ញុំ ហើយនិងធ្វើខ្លួនឲ្យភាគច្រើននៃប្រជារាស្ត្រព្រមទទួលយកនោះនៅឡើយ ។ សឺន-សាន់គាត់កាន់តែចាស់ ហើយកូនប្រុសរបស់ខ្ញុំ រណប្ញទ្ធិ គឺជាមេបញ្ជាការដ៏ល្អ តែគ្រប់គ្នាមិនព្រមទទួល ។ នៅឡើយ... ពេលខ្ញុំស្នើអ្វីមួយ សំណើររបស់ខ្ញុំត្រូវបដិសេធ មិនមែនត្រឹមតែបច្ចាមិត្រនៃរដ្ឋាភិបាលចំរុះប៉ុណ្ណោះទេ សូម្បីតែអ្នកធានា និងដៃគូរបស់ខ្ញុំនៅក្នុងរដ្ឋាភិបាលចំរុះ ។ អីចឹងទៅខ្ញុំគ្មានបានការអ្វីទាំងអស់ ។ ខ្ញុំគ្មានអំណាច

ខ្ញុំឥឡូវនេះអាយុ៦៨ឆ្នាំហើយ ។ ខ្ញុំប្រហែលរស់បាន២-៣ឆ្នាំទៀត ក៏ប៉ុន្តែដល់ថ្ងៃខ្ញុំទៅបាត់ឱកាសទាំងអស់នៅខាងយើង ដើម្បីដណ្តើមយកស្រុកខ្មែរពីវៀតណាមមកវិញ ក៏នឹងបាត់បង់ទៅជាមួយគ្នាផងដែរ ។

*(កកន ៖ការដណ្តើមយកស្រុកខ្មែរពីយួនមកវិញ វាមុខជាទៅចុះរណ្តៅជាមួយគាត់មិនខាន ។ សំដីរបស់គាត់ខាងលើនេះគ្រាន់តែសំរាប់ករឲ្យស្រីអាមេរិកាំងនេះស្តាប់លេងប៉ុណ្ណោះ ។ តាមពិតគឺគាត់ហ្នឹងហើយដែលបាន ធ្វើឲ្យទឹកដីកម្ពុជាក្រោមធ្លាក់ទៅក្នុងកណ្តាប់ដៃយួន នៅក្រោមរាជ្យរបស់គាត់កាលពីឆ្នាំ១៩៤៩ ? ប្រហែល១០ឆ្នាំក្រោយមក គាត់ក៏ហក់ទៅជួយយួនដដែលដោយហៅមកធ្វើផ្លូវលំហូ-ជីមិញឆ្លងកាត់ទឹកដីខ្មែរ ។ គាត់អនុញ្ញាតឲ្យយួនតាំងមូលដ្ឋានទ័ពនៅក្នុងទឹកដីខ្មែរ ។ គាត់ជួយដឹកកងទ័ព អាវុធ និង ស្បៀងទៅឲ្យយួនដើម្បីច្បាំងជាមួយអាមេរិកាំង ។ នៅដើមឆ្នាំ១៩៧០ ពេលប្រជាពលរដ្ឋខ្មែរនាំគ្នាដង្ហែគាត់ចុះចេញពីតំណែងប្រមុខរដ្ឋគាត់ស្រាប់តែហក់ទៅធ្វើជា «ស្តេចយួន» ហើយលើកទ័ពទីងចូលមកឈ្លានពានវាយប្រហារស្រុកខ្មែរ ។ លើសអំពីនេះទៀត គាត់បានទៅចូលរួមដៃជាមួយពួកបនឃាតករខ្មែរក្រហម ដែលយួនជាអ្នកបំពាក់អាវុធបំពាក់ស្មារតី ឲ្យធ្វើការកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរសឹងពាយអស់មួយនគរ ។ ចុងក្រោយបង្អស់ គាត់បានបោកពលរដ្ឋខ្មែរធ្វើ «កងទ័ពសីហនុនិយម» នាំគ្នាទៅឲ្យពួកយួនសម្លាប់ស្អុយព្រៃ ដែលតាមការពិតគាត់អបអរគាំទ្រថ្ងៃ «ជ័យជំនះ៧មករា១៩៧៩» យ៉ាងអ៊ឹងកង់ទៅវិញសោះ ។ យើងយល់ថា បើគ្មានស្តេចសីហនុទៅចូលដៃចូលជើងជាមួយយួន ស្រុកខ្មែររបស់យើងពិតជាពុំបានជួបប្រទះនឹងមហន្តរាយដូចកន្លងមកនេះទេ ។ បើពោលឲ្យចំទៅ នរោត្តម-សីហនុគឺជា «ស្តេចក្បត់ជាតិ» យ៉ាងពិតប្រាកដណាស់) ។*

ប៉្លេប៊ិយ ៖ តើរឿងហ្នឹងវាធ្វើឲ្យព្រះអង្គខ្លាចរន្ធត់ឬទេ ?

នរោត្តម-សីហនុ ៖ ខ្ញុំមិនខ្លាចរន្ធត់ទេ គឺអំពើយង់ឃ្នងរបស់ពួកខ្មែរក្រហមទេ ដែលត្រូវខ្លាចរន្ធត់ ។ ក៏ប៉ុន្តែការចាញ់សង្គ្រាម, ការបាត់បង់ស្រុករបស់ខ្លួន គឺជាអារម្មណ៍មានទុក្ខព្រួយ ។ កញ្ញាដឹងទេ... នៅរាល់យប់ ខ្ញុំលេបថ្នាំឲ្យងងុយគេង បើមិនដូច្នោះទេ ខ្ញុំមិនអាចគេងលក់ ពីព្រោះមកពីខ្ញុំមានទុទិដ្ឋិនិយម, ច្រាសច្រាលព្រួយបារម្ភ, កើតទុក្ខ ។

ប៉្លេប៊ិយ ៖ នៅក្នុងកំណត់ហេតុរបស់ព្រះអង្គ ព្រះអង្គបានសរសេរថា ពេលព្រះអង្គបានក្លាយជាព្រះមហាក្សត្រ ព្រះអង្គមានការយលសប្តិអាក្រក់ឡើងវិញ អំពីព្រះអង្គប្រឡងធ្លាក់វិទ្យាល័យ ។ តើព្រះអង្គនៅមានការយលសប្តិអាក្រក់បែបនេះដែរឬទេ ?

នរោត្តម-សីហនុ ៖ ចាស៎, ក៏ប៉ុន្តែឥឡូវនេះ ការយលសប្តិអាក្រក់គឺជានិច្ចអំពីអំពើ ឃោរឃៅរបស់ប៉ុល-ពតនិងខ្មែរក្រហម ឬអំពីការធ្វើឲ្យវិនាសខ្ទេចខ្ទាំស្រុករបស់ខ្ញុំដោយសារពួកវៀតណាម ។ មានជួនកាល ខ្ញុំបានឃើញកូនស្រីដ៏ជាទីស្រឡាញ់នៅក្នុងសប្តិរបស់ខ្ញុំ, សុរិយារង្សី, ដែលត្រូវប៉ុល-ពតសម្លាប់ ។ ខ្ញុំយលសប្តិបែបនេះ ។ ហើយចាស៎... ជួនកាលខ្ញុំយលសប្តិឃើញពួកវៀតណាម ។ ពួកគេមកដោយជិះក្នុងឡាន, ឡានជីលុច ។ ហើយខ្ញុំឈរនៅទីនោះ, ស្លៀកតែពាក់កណ្តាលខ្លួន, ចំហដើមទ្រូង, ជើងទទេ ។ ហើយពួកវៀតណាមមកដល់ រួចនិយាយមកកាន់ខ្ញុំ «សូមមកជាមួយយើង» ។ ខ្ញុំនិយាយថា «ខ្ញុំមិនអាចចេញក្រៅផ្ទះបានទេ... ខ្ញុំអត់ខោអាវ ។ ខ្ញុំមានតែសារុងមួយចង្កេះ» ។

ប៉្លេប៊ិយ ៖ តើព្រះអង្គគិតថា សប្តិនោះមានន័យយ៉ាងណាដែរ ?

នរោត្តម-សីហនុ ៖ ខ្ញុំគិតថា ខ្ញុំគឺដូចជាអ្នកក្រីម្នាក់... មនុស្សទនលគក ដែលពុំអាចទៅចូលរួមជាមួយពួកវៀតណាម និងពុំអាចថែរក្សាស្រុកខ្ញុំបានឡើយ ។ ពីព្រោះគឺខ្ញុំដូចជាមនុស្សគ្មានខោអាវ ។ ហើយជាមួយថ្នាំគេងលក់ ខ្ញុំដូចជាមនុស្សស្លាប់គ្មានយលសប្តិ ។

*(កកន ៖ ដោយសារសំដីនេះ យួនក៏បោះខោអាវឲ្យគាត់ពាក់ ពោលគឺបានបោះរាជបល្ល័ង្កឲ្យគាត់ឡើងសោយរាជ្យជាលើកទី២ ។ ម៉្លោះហើយ គាត់ក៏រត់ត្រួយ តោងតាមកន្ទុយឡានយួន ហើយប្រមូលកូនប្រមូលចៅមកកាច់សំបុកស៊ីអាចម៍ពួកអាយ៉ងយួនហ៊ុន-សែនជុះចោលនៅចំទន្ទេបួនមុខ ជាប់រហូតមកដល់សព្វថ្ងៃនេះ) ។*

ប៉្លេប៊ិយ ៖ តើព្រះអង្គខ្លាចស្លាប់ឬទេ ?

នរោត្តម-សីហនុ ៖ ទេ, អត់សោះ ។ ខ្ញុំមិនខ្លាចទេ តែខ្ញុំខ្លាចជីវិតជាតិក្រោយ ។

*(កកន ៖ មានតែមនុស្សដែលសាងអំពើអាក្រក់ក្នុងជាតិនេះទេ ដែលខ្លាចជីវិតនៅជាតិក្រោយ ។ ពីព្រោះមិនដឹងត្រូវធ្លាក់នរកដល់ជាន់ណា ។ នៅក្នុងអត្ថបទរបស់គាត់មួយគាត់បានសរសេរថា ៖ គាត់សូមបន់ស្រន់ ដល់ជាតិក្រោយកុំឲ្យជួបលោកស៊ឹម-វ៉ារទៀត ។ លោកលឹម-គឹមយ៉ានៅស្រុកបារាំងបានឆ្លើយថា ៖ ចំពោះរឿងនេះសូមសម្តេចកុំភ័យឲ្យសោះ នៅជាតិក្រោយព្រះអង្គពិតជាមិនបានជួបលោកស៊ឹម-វ៉ារទៀតទេ ពីព្រោះលោកស៊ឹម-វ៉ារពេលស្លាប់ទៅគាត់ឡើងស្ថានសួគ៌ រីឯចំណែកឯព្រះអង្គវិញដល់ពេលស្លាប់ទៅ ព្រះអង្គទៅទឹកខ្ទែងខុសគ្នា) ។*

ប៉្លេប៊ិយ ៖ ព្រោះហេតុអីទៅ ?

នរោត្តម-សីហនុ ៖ ខ្ញុំអាចមានជីវិតអាក្រក់អាក្រីនៅជាតិក្រោយ ។ បើខ្ញុំកើតឡើងវិញនៅស្រុកស្វីស ឬនៅសហរដ្ឋអាមេរិក គឺមិនអីទេ ។ តែបើប្រសិនណាខ្ញុំទៅជួបជាមួយប៉ុល-ពតមួយទៀត ឬមួយក៏រស់នៅក្រោមវៀតណាម និងហេង-សំរិន ។ ឬមួយឧបមាថា ខ្ញុំក្លាយទៅជាកូនង៉ែតកើតនៅក្នុងជំរំជនភៀសខ្លួនក្រោមប៉ុល-ពតនៅស្រុកសៀម... នោះគឺអាក្រក់ខ្លាំងពន់ពេកណាស់ ។

*(កកន ៖ តើស្តេចសីហនុនិងប៉ុល-ពតមានអ្វីខុសពីគ្នាទៅ ? ចូលដៃចូលជើងជាមួយយួនដូចគ្នា ។ បាតដៃប្រឡាក់ឈាមខ្មែរដូចគ្នា ។ ម៉្លោះហើយ នៅក្នុងសតិអារម្មណ៍របស់ស្តេចសីហនុ គឺមានតែអំពើបាបកម្មដែលតាមបុករុកថ្ងើមប្រមាត់បេះដូងរបស់គាត់គ្មានល្ហែល្ហៃ ។ យើងចង់ដឹងណាស់ តើសព្វថ្ងៃគាត់រស់នៅដោយសារអ្នកណា និងក្រោមរបបអ្នកណា ?) ។*

ប៉្លេប៊ិយ ៖ គ្រប់ៗគ្នាបានឮអំពីអំពើឃោរឃៅព្រៃផ្សៃរបស់ពួកខ្មែរក្រហម ។ ភាគច្រើនបានឃើញទីលានពិឃាត ។ ក៏ប៉ុន្តែវា

ពិបាកយល់ថា តើហេតុអ្វីបានកើតមានយ៉ាងដូច្នេះ ។ តើខ្មែរក្រហមជានរណា ? តើពួកគេមកពីណា ?

នរោត្តម-សីហនុ ៖ មុនសង្គ្រាមឆ្នាំ១៩៧០, ស្រុកខ្មែរមានប្រជាជនជាង៧,០០០,០០០នាក់ ។ យើងស្លូតបូតសុភាពរាបសារ, ជាមនុស្សមានអធ្យាស្រ័យ, រស់នៅយ៉ាងសុខសាន្ត, ម្នាក់ៗមានសិទ្ធិសេរីភាព ហើយបូជាចំពោះសាសនា ។ ប្រជារាស្ត្រខ្មែរប្រាំមួយលាននាក់ជាពុទ្ធសាសនិក, ចំនួនប្រហែល៥០០,០០០នាក់ជាមូស្លីម និងចំនួនប្រហែល៥០,០០០នាក់ជាកាតូលិក ។ កសិកម្មរបស់យើងចំរើនរុងរឿង ។ ដីយើងមានជីរជាតិល្អ ។ រៀងរាល់ឆ្នាំ យើងអាចនាំចេញនូវស្រូវលើស, ពោត, កៅស៊ូ, ត្រី ។ សូម្បីមិនធ្វើការពិបាកក៏ដោយ ក៏យើងអាចរស់នៅដោយសុខស្រួលដែរ ។

ក៏ប៉ុន្តែមានរួចទៅហើយកាលពីអំឡុងឆ្នាំ៥០ យើងមានពួកកុម្មុយសិស្តពីរធុន ។ មួយក្រុមអប់រំដោយហាណូយ... ដោយអ្វីដែលគេហៅថាគណបក្សកុម្មុយនិស្តឥណ្ឌូចិនដឹកនាំដោយហូ-ជីមិញ ។ ក្រុមទីពីរគឺពួកបញ្ញវ័ន្តខាងឆ្វេង ដែលសិក្សារៀនសូត្រនៅស្រុកបារាំង ហើយបានក្លាយខ្លួនជាជនកុម្មុយនិស្ត ។ ខ្ញុំហៅពួកគេថា Khmer Rouge. Khmer មានន័យថា ខ្មែរ... Rouge គឺក្រហម... ខ្មែរក្រហម ។

ពេលនោះខ្ញុំជាស្តេចស្រុកខ្មែរ ហើយបានសង់សាលាបឋមសិក្សា និងមធ្យមសិក្សាសំរាប់ប្រជារាស្ត្ររបស់ខ្ញុំ ។ ក៏ប៉ុន្តែសកលវិទ្យាល័យពុំទាន់សង់នៅឡើយទេកាលពីជំនាន់ឆ្នាំហុកសិប ។ ពេលបញ្ចប់មធ្យមសិក្សា យើងមានទម្លាប់បញ្ជូនសិស្សល្អៗទៅស្រុកបារាំង ។ ដូច្នេះហើយ ប៉ុល-ពត, សុន-សេន, ខៀវ-សំផន, អៀង-សារី, ពួកជនទាំងអស់ដែលពិភពលោកស្គាល់ថាជាមេខ្មែរក្រហម បានទទួលនូវអាហារូបករណ៍ពីខ្ញុំទៅសិក្សានៅឯស្រុកបារាំង ។

ប៉្លេប៊ិយ ៖ ដូច្នេះរដ្ឋាភិបាលរបស់ព្រះអង្គ បានចំណាយលើការរៀនសូត្ររបស់ពួកគេ ?

នរោត្តម-សីហនុ ៖ ចាស៎, រដ្ឋាភិបាលបានចំណាយ ។ (សើច) ហើយពួកគេបានទទួលនូវឥទ្ធិពលដោយការរៀនសូត្ររបស់ពួកគេនៅស្រុកបារាំង ។ បើកញ្ញាបានអានប្រវត្តិសាស្ត្របដិវត្តន៍បារាំង នោះពិតជាស្មុគស្មាញខ្លាំងណាស់ តែជារយៈកាលបង្ហូរឈាមដ៏អស្ចារ្យ ដែលគេហៅថា La Terror... អំពើភេរវកម្ម... គឺជាពេលបដិវត្តន៍ដែលចាប់ផ្តើមដោយការកាត់ក្បាលស្តេច ហើយនិងពួកអភិជន...រួចដល់ក្រោយមក ក៏ធ្វើ«អំពើភេរវកម្ម»នៅក្នុងចំណោមពួកគេ ។ ពួកខ្មែររៀនសូត្រនៅស្រុកបារាំងទាំងនោះមានការចាប់ចិត្តចំពោះអំពើភេរវកម្ម ។ ហើយដល់ពេលពួកគេវិលត្រឡប់មកពីស្រុកបារាំងវិញ ពួកគេក៏ចង់ធ្វើបដិវត្តន៍ ។ ពេលនោះ ខ្ញុំក៏បានរៀបចំចំណងទូតជាមួយសាធារណរដ្ឋប្រជាមានិតចិនហើយដែរ ហើយពួកគេក៏បានហៅឲ្យទៅសិក្សារៀនសូត្រលទ្ធិកុម្មុយនិស្តនៅទីនោះ ។ ពួកគេចូលចិត្តលទ្ធិកុម្មុយនិស្តចិន ។ ពួកគេជក់ចិត្តនឹងបដិវត្តន៍វប្បធម៌របស់ម៉ៅ ។

*(កកន ៖ ពេលមុននេះបន្តិច គាត់ទើបអួតក្រេវៗថា ម៉ៅ-សេទុង គឺជាវីរៈបុរសរបស់គាត់ ហើយគាត់តែងតែសន្មត់ខ្លួនគាត់ថាជា «ស្តេចក្រហម» (Prince rouge) ។ នៅពេលគាត់បង្កើត «រណសិរ្សរួបរួមជាតិកម្ពុជា» (FUNK) និងបង្កើត«រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (GRUNK) នៅប៉េកាំងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ តើសមាជិកដ៏ច្រើនលើសលប់នោះពុំមែនសុទ្ធជាពួកខ្មែរក្រហម ដែលលើកម៉ៅ-សេទុងទូលលើក្បាលដូចគាត់ដែរទេឬ ? ។ តើពុំមែនពួកខ្មែរក្រហមនេះទេឬ ដែលបានបោះតំណែង«ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យអស់មួយជីវិត»ឲ្យគាត់ នៅពេលចាប់ផ្តើមថ្ងៃទីលានពិឃាត «១៧ មេសា ១៩៧៥» ? ។ ហើយឥឡូវនេះ តើគាត់កំពុងរស់នៅឯណា និងស៊ីបាយរបស់អ្នកណា ? ។ បើគេស្តាប់សុន្ទរកថារបស់គាត់ ដែលគេចាក់ផ្សាយនៅតាមវិទ្យុចិនប៉េកាំង កាលពីជំនាន់ឆ្នាំ៧០ ការសរសើរពួកខ្មែរក្រហម និងការសរសើរចិន ស្តាប់ទៅគួរឲ្យព្រឺក្បាលខ្លាំងណាស់) ។*

ប៉្លេប៊ិយ ៖ បដិវត្តន៍វប្បធម៌ខ្លាំងហួសហេតុក្រៃលែង ពាក់ព័ន្ធនឹងការបែកបាក់ព្រមទាំងការធ្វើទុក្ខបុកម្នេញយ៉ាងច្រើន ដែលសូម្បីតែពួកមេដឹកនាំនៅប៉េកាំងបច្ចុប្បន្ន ក៏ថ្កោលទោសមហន្តរាយនេះដែរ ។ តើនេះឬដែលជាគំរូរបស់ខ្មែរក្រហមនោះ ? ។

នរោត្តម-សីហនុ ៖ ខ្មែរក្រហមគាត់មិនចង់ធ្វើត្រឹមតែជាជនកុម្មុយនិស្តនោះទេ ។ ពួកគេចង់ធ្វើជាអ្នកចុងពោចបំផុត ។ ទស្សនៈរបស់ពួកគេ គឺបញ្ចូលគ្នារវាងលទ្ធិអ៊ីត្លែរ និងលទ្ធិបដិវត្តន៍វប្បធម៌ចិន ។ ពួកគេចង់ឲ្យស្រុកខ្មែរមានឈ្មោះ នៅក្នុងប្រវត្តិសាស្ត្រ ជាស្រុកមួយមានអំណាចខ្លាំងពូកែជាងកាលពីជំនាន់អង្គរ ចន្លោះពីសតវត្សរ៍ទី៩ដល់ទី១២ទៅទៀត ជាពេលដែលរាជាណាចក្រខ្មែរចាស់ត្រួតត្រាពេញមួយផ្នែកនេះនៃពិភពលោក ។ ហើយដើម្បីឲ្យក្លាយទៅជាប្រជាជាតិមួយដ៏អស្ចារ្យ, ពួកគេនិយាយថា, គ្រប់ៗគ្នាត្រូវតែស្វិតស្វាញ ដូចពួកជនស្ប៉ាតា (Sparta) នៅប្រទេសក្រិកជំនាន់ដើមអឺថែន ។ ហើយ ពួកគេមានជំនឿជឿជាក់ថា ពួកគេអាចមានជោគជ័យ ។ ខ្មែរមានហេតុផលគឺថា ៖ ចាប់តាំងពីយើងច្បាំងឈ្នះពួកអាមេរិកាំង ហើយមានជោគជ័យដោយមានកងទ័ពដ៏ពូកែអស្ចារ្យក្នុងពិភពលោក តើហេតុអ្វីយើងត្រូវមកបរាជ័យក្នុងការប៉ុនប៉ងចង់ធ្វើឲ្យជាតិទាំងមូលបរិសុទ្ធ, ខ្លាំងពូកែ, មានថ្វីដៃដូចគ្នាទៅនឹងកងទ័ពរបស់យើង ?

ប៉្លេប៊ិយ ៖ ដូច្នេះវត្ថុបំណងរបស់ពួកគេ គឺចង់បង្វឹលជាតិទាំងមូលឲ្យទៅជាកងទ័ពឬ ?

នរោត្តម-សីហនុ ៖ ចាស៎... ពួកគេមានបីដំណាក់ ក្នុងការធ្វើឲ្យសំរេចនូវសុបិនរបស់ ពួកគេដើម្បីបង្កើតសង្គមថ្មី ៖ បណ្តេញប្រជាជនទាំងអស់ ចេញពីទីក្រុងភ្នំពេញនិងទីក្រុងផ្សេងទៀតទៅកាន់ទីជនបទ ។ កសាងកងទ័ពមួយដ៏ខ្លាំងពូកែ, ដ៏ស្វិតស្វាញអស្ចារ្យនិងមានប្រសិទ្ធិភាពជាងគេបំផុតនៅក្នុងពិភព លោក ។ ហើយនិងកំទេចចោលអំពើពុករលួយ ព្រមទាំងធាតុមិនអាចកែប្រែបានទាំងអស់ ដែលធ្វើឲ្យសង្គមខ្ជិនខ្ជង់ ព្រមទាំងអ្នកណាដែលមិនអាចកែច្នៃបាន ឲ្យក្លាយទៅជាជនកម្ពុជាបែបថ្មី ។ ខ្មែរក្រហមមិនចូលចិត្តការសប្បាយនឹងរស់របស់យើងទេ ។ យើងដូចគ្នាទៅនឹងពលរដ្ឋនៅរដ្ឋហាវ៉ៃរបស់អ្នកឯង ឬនៅតាហ៊ីទីបារាំងអឺថែង គឺច្រៀង រាំ ផឹងមោងគ្នា ស៊ីឆ្ងាញ់ ។ ខ្មែរក្រហមយល់ថា ប្រជាជនខ្មែរខ្ជិលច្រអូស ហើយគ្មានបានការ ។ បើយើងមិនផ្លាស់ប្តូររបៀបរស់នៅទេ យើងមិនអាចក្លាយខ្លួនជាមហាអំណាច ដូចកាលពីមុននោះឡើយ ។ ម្លោះហើយដើម្បីកសាងសង្គមថ្មី ពួកគេត្រូវតែលុបបំបាត់ចោលអារ្យធម៌និងទំនៀមទំលាប់ប្រពៃណីរបស់យើង ។ រួចហើយពួកគេលុបបំបាត់ចោលព្រះពុទ្ធសាសនា ពីព្រោះព្រះពុទ្ធសាសនានិយាយថា «សូមមានការអត់ឱន... សូមកុំធ្វើចំបាំង... កសាងសន្តិភាព» ។ ព្រះពុទ្ធសាសនាមិនល្អសំរាប់ធ្វើឲ្យពួកអ្នកធ្វើចំបាំងខ្លាំងពូកែឡើយ ។

*(កកន ៖ យើងមិនដឹងថា តើជាសំដីរបស់ពួកខ្មែរក្រហមនិយាយចេញមក ឬមួយក៏ជាសំដីរបស់ស្តេចសីហនុនោះទេ... ពីព្រោះសំដីបែបនេះស្តេចសីហនុនិយាយចេញមកដូចគ្នា ជាពិសេសការប្រើពាក្យថា «យើង» ។ សូមស្តាប់សំដីរបស់ស្តេចសីហនុ ពេលគាត់ផ្តល់សម្ភាសន៍ចំពោះលោក Alain Peyrefitte អតីតរដ្ឋមន្ត្រីការបរទេសបារាំង ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តី PARIS MATCH លេខ១៣៥៣ ថ្ងៃទី៣ ឧសភា ឆ្នាំ១៩ ៧៥ ចុះ ៖*

*«ទីក្រុងភ្នំពេញបានត្រាំជោគជាំដោយការចូលរួមដៃរួមគំនិតជាមួយ គ្នា ។ គឺជាមុខរបួសក្លាយ ដែលស្ថិតនៅលើមុខមាត់កម្ពុជាស្ទួតត្រង់ ។ ព្រះមហាក្សត្រីយ៍មាតាបានបោះបង់ចោលរូបខ្ញុំ ពេលខ្ញុំបែរខ្នង ។ ខ្ញុំនឹងធ្វើឲ្យគាត់អាម៉ាស់មុខ ។ ពួកជនថ្នាក់កណ្តាលនៅភ្នំពេញ ដែលបានក្បត់នឹងមេដឹកនាំរបស់ខ្លួន និងក្បត់មាតុភូមិរបស់ខ្លួន, ខ្ញុំនឹងធ្វើឲ្យពួកគេអាម៉ាស់មុខ ៖ គឺត្រូវផ្តន្ទាទោសពួកគេ ។ ខ្ញុំនឹងមិនចូលទៅក្នុងទីក្រុងជាមួយកងទ័ពទេ, ខ្ញុំនឹងបណ្តេញពួកគេចេញឲ្យអស់ជាមុនសិន ។ ខ្ញុំមិនចង់ទៅនៅទីនោះទេ ក្រោយពេលរំដោះ ។ ជាជំនួស ខ្ញុំនឹងមានផ្ទះឈើប្រក់ស្លឹកមួយ សង់សំរាប់ខ្ញុំក្នុងព្រៃអង្គរ ។ ហើយនៅទីនោះ ប្រជារាស្ត្រអាចចូលមកសួរសុខទុក្ខខ្ញុំ ។ ភ្នំពេញជាទីក្រុង Vichi ។ លន់-នល់គឺជា Laval ។ ខ្ញុំនឹងឲ្យគេបាញ់សម្លាប់គាត់ចោលយ៉ាងពិតប្រាកដណាស់ ។ ក៏ប៉ុន្តែដោយសារគាត់ជាខ្មែរ ហើយប្រជារាស្ត្រខ្មែរក៏ជាកូនចៅរបស់ខ្ញុំ, ខ្ញុំនឹងឲ្យគេបាញ់សម្លាប់ពួកគេចោល ដោយភាពថ្នាក់ថ្នម» (sic) ។*

*តើទាំងអស់នេះពុំមែនជាផែនការរបស់ស្តេចសីហនុទេឬ ? ។ គាត់គឺជាអ្នកចេញបញ្ជា ឲ្យបណ្តេញប្រជាពលរដ្ឋចេញពីក្រុងភ្នំពេញ និងពីក្រុងនានាទៅកាន់ទីជនបទស្រែចំការ ។ គាត់គឺជាអ្នកចេញបញ្ជា ឲ្យបាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរ ដើម្បីជាការលាងគំនុំសងសឹក ។ សូម្បីតែការផែនការផ្លាស់ប្តូររបបនៅក្នុងស្រុកខ្មែរ ក៏ជាផែនការរបស់ស្តេចសីហនុដែរ ។ ស្តេចសីហនុគាត់បានសរសេរចុះផ្សាយនៅក្នុងកាសែត «អ្នកជាតិនិយម» តាំងពីថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៥៥មកម៉្លេះថា ៖ ម្ភៃឆ្នាំទៅមុខនេះ របបនៅស្រុកខ្មែរនឹងក្លាយជារបបខ្មែរក្រហម ។ ពោលគឺគាត់រៀបក្រឡាឲ្យពួកខ្មែរក្រហមឡើងក្តាប់អំណាចរួចជាស្រេច ។ លោកលន់-នល់និងរបបសាធារណរដ្ឋខ្មែរ គ្រាន់តែជាកូនអុករបស់គាត់សំរាប់រុញលេងតែប៉ុណ្ណោះ ។ បើនិយាយឲ្យចំ «របបសាធារណរដ្ឋខ្មែរ» គឺជាផែនការរបស់ស្តេចសីហនុសុទ្ធសាធ សំរាប់ធ្វើជាឈ្នាន់ដើម្បីឲ្យគាត់និងពួកខ្មែរក្រហម ឈោងទៅចាប់អំណាចនៅក្នុងស្រុកខ្មែរនៅក្នុងឆ្នាំ១៩៧៥ ។*

*នយោបាយផ្តាច់ផែនដីដើម្បីដាំស្មៅឡើងវិញនេះ តាមពិតទៅគឺគ្មាននរណាក្រៅអំពីជារបស់ស្តេចសីហនុនេះទេ ។ គាត់ចង់មានឈ្មោះល្បីដូច ម៉ៅ-សេទុង ឬដូចហូ-ជីមិញ ។ ដើម្បីបំពេញមហិច្ឆិតាឆ្កួតវង្វេងរបស់គាត់ ៗអត់ខ្វល់នឹងនរណាង៉ាប់នៅឯណាក៏ង៉ាប់ទៅ ឲ្យតែអង្គអញមានមុខមាត់ ។ បើចំកួតហួងម្នាក់នេះចេះគិតគូរដល់អាយុជីវិតរបស់ប្រទេសជាតិនិងសេចក្តីសុខរបស់រាស្ត្រ មិនមែនគាត់ហក់ទៅធ្វើជា«ស្តេចយួនយៀកកុង» ហើយកេណ្ឌគរលើកទ័ពទីងចូលវាយប្រហារស្រុកខ្មែរយ៉ាងដូច្នោះឡើយ ជាពិសេសគាត់មិនមែនទៅចូលដៃចូលជើងជាមួយពួកបនយាតករខ្មែរក្រហម ប្រព្រឹត្តអំពើសម្លាប់រង្គាលជាតិសាសន៍ខ្លួនឯងនោះដែរ ។*

*ដល់ពេលពិភពលោកគេថ្កោលទោសអំពើឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម ស្តេចពព្រាក់ពព្រើតនេះក៏ប្រញាប់ប្រញាល់រលាស់ឈាមចេញពីបាតដៃ ហើយស្រែកអ៊ឹងកងយករួចខ្លួនយ៉ាងរំភើយ ។ នេះហើយជាពុតត្បុតយ៉ាងក្រាស់ឃ្មឹករបស់ស្តេចសីហនុ ដែលពុំមានមេដឹកនាំស្រុកឯណានៅក្នុងពិភពលោកអាចធ្វើដូច ។*

*មានជនរាជានិយមខ្លះបានតវ៉ាថា យើងចូលចិត្តគាស់កកាយរឿងចាស់ៗរបស់ស្តេចសីហនុ លើកយកមកធ្វើជាឧបករណ៍ដើម្បីវាយប្រហារទៅលើស្តេចសីហនុ ។ ត្រង់ចំណុចនេះយើងសូមបញ្ជាក់ថា ពុំមែនយើងទេដែលចូលចិត្តធ្វើបែបនេះ ។ គឺស្តេចសីហនុខ្លួនឯងទេតើ ដែលបានទៅជ្រាវរាវរកឯកសារចាស់ៗទាំងអស់នេះពីបាតហិប ឬពីក្នុងថតតុយកមកចុះផ្សាយតាមទំព័រវេបសាយរបស់គាត់ ដើម្បីក្នុងវត្ថុបំណងចង់កែខ្លួនឲ្យគេឯងគ្រប់ៗគ្នាបានឃើញថា គាត់ជាមនុស្សល្អល្អាច់ ពុំដែលបានកសាងកំហុសអ្វីសោះឡើយ ។ អ្នកដែលធ្វើកំហុសបណ្តាលឲ្យជាតិលិចលង់វិនាសអន្តរាយនោះ គឺជាអ្នកដទៃក្រៅពីគាត់ ដូចជាលោកសឺង-ង៉ុកថាន់, លោកលន់-នល់ និងប៉ុល-ពតជាដើម ។ល។ ក៏ប៉ុន្តែបើយោងតាមឯកសារដែលយើងមាន វាខុសផ្ទុយគ្នាស្រឡះពីឯកសាររបស់គាត់ ។ ឧទាហរណ៍ដូចជាបទសម្ភាសន៍ដែលគាត់បានធ្វើជាមួយទស្សនាវដ្តីប៉េប៊យនេះជាដើម ។ នៅក្នុងវិបសាយរបស់គាត់ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ គាត់បានចុះផ្សាយអត្ថបទសម្ភាសន៍នេះជារបៀបបកស្រាយរបស់គាត់ (Sihanouk's version) ដែលគាត់ដកស្រង់តែចំណុចណាល្អៗដើម្បីលើកកំពស់ខ្លួនគាត់ ។ អត្ថបទនោះបើតាមយើងយល់ គឺប្រហែលជាអត្ថបទដែលគាត់បានផ្ញើទៅសុំកញ្ញា Debra Weiner ឲ្យយកទៅចុះផ្សាយនៅក្នុងទស្សនាវដ្តី Playboy ជំនួសអត្ថបទសម្ភាសន៍ទី១ ដែលគាត់បានធ្វើដោយពព្រាក់ពព្រើត ដោយឡេះឡោះ ឬដោយការស៊ីជោររបស់គាត់ ។ ក៏ប៉ុន្តែកញ្ញា Debra Weiner ពុំបានធ្វើតាមសំណូមពររបស់គាត់ទេ គឺកញ្ញាបានលើកយកបទសម្ភាសន៍ដើមទាំងមូល (ទាំងស្រុង) មកចុះផ្សាយតែម្តង ។ ចំពោះរឿងនេះ យើងសូមបញ្ជាក់ប្រាប់ទៅជនសីហនុនិយមទាំងនោះវិញថា យើងជាប្រជានុរាស្ត្រតូចតាច ។ អ្វីៗដែលយើងបានធ្វើ គឺគ្រាន់តែចង់ដង្ហែតាមក្រោយកន្ទុយព្រះអង្គប៉ុណ្ណោះ ពុំដែលហ៊ានដណ្តើមដើរពីមុខព្រះអង្គម្តងណាសោះឡើយ) ។*

ប្លេប៊យ ៖ ក៏ប៉ុន្តែតើហេតុដូចម្តេចបានជាសម្លាប់មនុស្សម្នាច្រើនម្ល៉េះ ?

នរោត្តម-សីហនុ ៖ គឺដូចស្តាលីន ពេលដែលគាត់នៅក្រឹមឡាំងអីចឹង, ខ្មែរក្រហមភ្នែកឃើញសត្រូវនៅគ្រប់ទិសទី ។ ពួកបញ្ញវ័ន្តដែលមិនដូចពួកគេ គឺសុទ្ធជាពួកបញ្ញវ័ន្តពុករលួយ ហើយត្រូវកំទេចចោលទាំងអស់ ។ ពួកគេនិយាយថា ពួកស្តេចក៏ត្រូវកំទេចចោលដែរ ពីព្រោះជាអ្នកជិះជាន់សង្កត់សង្កិនលើរាស្ត្រ ។ ខ្ញុំមិនដែលជិះជាន់សង្កត់សង្កិនប្រជារាស្ត្ររបស់ខ្ញុំទេ ។ ខ្ញុំសង់សាលារៀន សាកលវិទ្យាល័យ មន្ទីរពេទ្យឲ្យពួកគេ ។ ប្រជារាស្ត្រគ្មានមូលហេតុអ្វីស្អប់ខ្ពើមរាជានិយមឡើយ ។ ក៏ប៉ុន្តែពួកខ្មែរកុម្មុយនិស្តយល់ថា ដើម្បីក្តាប់អំណាចពួកគេត្រូវតែសម្លាប់ស្តេច និងពួកមេដឹកនាំរាជានិយមទាំងអស់ ។ រួចហើយក្រោយបន្ទាប់ពីលុបបំបាត់ពួកស្តេច ពួកគេលុបបំបាត់ពួកសាធារណរដ្ឋមិនមែនស្តេច, ពួកអភិជន, ពួកអ្នកមាន, ពួកអ្នកជំនួញមានៗ, ពួកឧស្សាហករ... ហើយនិងពួកមនុស្សដែលក្រុមប៉ុល-ពត បានសំរេចចិត្តថា ជាខ្មាំងសត្រូវនឹងពួកអ្នកក្រ ។ ពីព្រោះដើម្បីធ្វើជាអ្នកមាន ពួកគេត្រូវតែចំរាញ់យកផលពីពួកអ្នកក្រ ។ នៅក្នុងប្រទេសកុម្មុយនិស្ត ខ្លះ, ពួកគេចាប់ពួកអ្នកមាន

ដាក់ក្នុងជំរំលត់ដំ ដើម្បីអប់រំសាជាថ្មី ។ ក៏ប៉ុន្តែពួកកុម្មុយនិស្តនៅស្រុកខ្មែរនិយាយថា «ទេ, ពួកមនុស្សទាំងអស់នេះពុំអាចអប់រំសាជាថ្មីបានឡើយ ។ យើងពុំអាចផ្លាស់ប្តូរចិត្តគំនិត ឬបេះដូងរបស់ពួកគេបានទេ ។ ពួកគេត្រូវតែកំទេចចោល» ។

ហើយកញ្ញាដឹងទេ... ខ្ញុំនិយាយអំពីពុទ្ធសាសនា ។ យើងមានព្រះសង្ឃចំនួន៨០,០០០អង្គ ។ ហើយបើយោងតាមពុទ្ធវិន័យ, ព្រះសង្ឃមិនអនុញ្ញាតឲ្យធ្វើការទេ ។ ព្រះសង្ឃត្រូវប្រជារាស្ត្រប្រគេនចង្ហាន់ ដើម្បីសូត្រធម៌ ប្រោះព្រំដល់យើងទាំងអស់គ្នា ។ ដូច្នេះប៉ុល-ពតនិងក្រុមរបស់គាត់និយាយថា ព្រះសង្ឃត្រូវតែលុបបំបាត់ ពីព្រោះធ្វើឲ្យសេដ្ឋកិច្ចទន់ខ្សោយ ។ ព្រះសង្ឃឆាន់បាយដែលផលិតដោយអ្នកស្រុក តែព្រះសង្ឃពុំបានចូលរួមចំណែកនៅក្នុងការកសាងសេដ្ឋកិច្ចឲ្យរុងរឿងទេ ។

ហើយក្រោយបន្ទាប់ពីហ្នឹងមក, ពួកក្រហមនិងក្រហមក៏ប៉ះទង្គិចគ្នា ។ ខ្មែរក្រហមចាប់ផ្តើមសម្លាប់គ្នាទៅវិញទៅមកដោយម្ខាងជ្រើសរើសស្ថិតនៅជាមួយហាណូយនិងមូស្គូ... មិននៅជាមួយចិនទេ... ព្រោះមិនអាចទុកចិត្តបាន ។ពួកគេធ្លាប់បាននិយាយថា «យើងចង់បានតែជនវណ្ណៈអធនពិតប្រាកដចំនួន១,០០០,០០០នាក់ប៉ុណ្ណោះ.... ជាប្រជាជនក្រីក្រសុទ្ធសាធ...ជាជាងមានមនុស្សរាប់លាននាក់ ដែលមិនអាចកែប្រែឲ្យទៅជាជនកុម្មុយនិស្តដ៏ល្អ និងពិតប្រាកដបាន» ។

ប៉ូប៊ិយ ៖ តើពួកគេធ្វើយ៉ាងដូចម្តេច អាចបង្វិលមនុស្សជាច្រើននាក់ឲ្យទៅជាឃាតករ ?

នរោត្តម-សីហនុ ៖ នៅកន្លែងលេងសៀក មានសត្វខ្លាដែលមនុស្សអាចផ្សាំសំរាប់លេងឲ្យគេមើល ។ ហេតុដូច្នេះហើយបើគេអាចផ្លាស់ប្តូរសត្វខ្លាឲ្យក្លាយទៅជាសត្វឆ្មាបាន នោះគេក៏អាចផ្លាស់ប្តូរសត្វឆ្មាឲ្យទៅជាសត្វខ្លាបានដែរ។ហើយពួកគេមានប្រជាជនខ្មែរដែលជាសត្វខ្លារួចទៅហើយផង ។ នៅក្នុងចំណោមពួកកុលសម្ពន្ធនៅប៉ាស៊ីហ្វិកខាងត្បូង, នៅម៉ាឡេស៊ីនិងឥណ្ឌូណេស៊ីជាដើម, មានមនុស្សចំឡែកខុសគេដែលគេហៅថា អាម៉ុក ។ ពេលជួនកាល មនុស្សបានត្រូវអាម៉ុកចូល ហើយក៏ក្លាយជាជនកំណាចឃោរឃៅ ។ យើងជាខ្មែរក៏មានអាម៉ុកដែរ ពីព្រោះយើងស្ថិតនៅក្នុងចំណោមគ្រួសារអូសេអានិកដូចគ្នា ។ ដូច្នេះប៉ុល-ពត... ដោយការបំបែកប្រជាជនក្រីក្រនិងប្រជាជនក្មេងៗចេញពីឪពុកម្តាយរបស់ពួកគេ ហើយអប់រំពួកគេឲ្យទៅជាសាសន៍ថ្មីមួយ,ជាសាសន៍ថ្មីដែលគេបង្ហាត់ឲ្យប្រឆាំងនឹងប្រជាជនខ្មែរ...គឺបង្កើតឲ្យមានមនោគមវិជ្ជា និងនយោបាយអាម៉ុកដ៏យូរអង្វែងមួយ ។

*(កកន ៖ ស្តេចសីហនុគាត់ចង់និយាយថា ខ្លួនគាត់ក៏ត្រូវ<អាម៉ុក>ស្អីគេនោះចូលដែរ បានជាគាត់ក្លាយខ្លួនជាជនពាលដ៏សាហាវឃោរឃៅអាចក្បត់ជាតិខ្លួនឯងហើយអាចសម្លាប់ជាតិខ្លួនឯង។ជនដែលអាម៉ុកចូល នេះមានតែមួយក្រុមតូចប៉ុណ្ណោះ ដែលវង្វេងឆ្កួតជ្រុកចាញ់បោកយួន ចាញ់បោកចិន... ឯចំណែកប្រជាពលរដ្ឋខ្មែររាប់លាននាក់ ដែលត្រូវពួកឃាតករនេះសម្លាប់ ពុំមានអាម៉ុកអាមុំងឯណាមកចូលឡើយ ។ គឺសុទ្ធជាប្រជាពលរដ្ឋស្លូតត្រង់ កាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ។ ជាអ្នកធ្វើបុណ្យដាក់ទាន ប្រកបដោយចិត្តមេត្តាករុណាយ៉ាងល្អប្រពៃណាស់) ។*

ប៉ូប៊ិយ ៖ តើការកាប់សម្លាប់ហើយនិងអំពើឃោរឃៅ គឺជាផ្នែកមួយនៃធម្មជាតិមនុស្សឬ ?

នរោត្តម-សីហនុ ៖ ចាស៎, មើលនៅក្នុងកញ្ចក់ទូរទស្សន៍របស់កញ្ញាទៅឃើញហើយ រាល់ថ្ងៃឃើញតែអំពើឃោរឃៅ ។ នៅគ្រប់ស្រុកទាំងអស់ គេមានមនុស្សឃោរឃៅដែលចូលចិត្តអំពើព្រៃផ្សៃ... ដែលចូលចិត្តធ្វើការកាប់សម្លាប់ ។ ហើយប៉ុល-ពតបានលើកទឹកចិត្តមនុស្សអស់នោះឲ្យធ្វើការកាប់សម្លាប់ ។

*(កកន ៖ នៅក្នុងបទសម្ភាសន៍ជាមួយលោក Alain Peyrefitte អតីតរដ្ឋមន្ត្រីការបរទេសបារាំង ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តី PARIS MATCH លេខ១៣៥៣ថ្ងៃទី៣ឧសភា ឆ្នាំ១៩៧៥ ស្តេចសីហនុចេញបញ្ជាឲ្យពួកខ្មែរក្រហមសម្លាប់លោកលន់-នល់ និងសម្លាប់ប្រជាពលរដ្ឋខ្មែរដោយ «កាពថ្នាក់ថ្មម»... តើនេះពុំមែនជាការបង្គាប់បញ្ជា ដែលលើសពីការលើកទឹកចិត្តទេឬ ? ។ តាមពិតទៅប៉ុល-ពតគឺចាំតែធ្វើតាមការបង្គាប់បញ្ជារបស់ស្តេចអាម៉ុកចំកួតហ្នឹងមួយអង្គនេះទេតើ !!) ។*

ប៉ូប៊ិយ ៖ តើព្រះអង្គគិតថា ប៉ុល-ពតដែលមានអារម្មណ៍សោកស្តាយក្រោយ, អារម្មណ៍ដឹងកំហុសឬទេ ? តើគាត់ដែលមានវន្ធត់នឹងឈាមនៅក្នុងដៃរបស់គាត់ឬទេ ?

នរោត្តម-សីហនុ ៖ ប៉ុល-ពតនិងក្រុមរបស់គាត់មិនដែលនិយាយថា ពួកគេបានធ្វើខុសទេ តែពួកគេបាននិយាយថា ពួកដឹងអំពីកំហុសរបស់ពួកគេ ។ សូមរំឭកអំពី អ៊ីត្លែរ ។ រំឭកអំពី ហ៊ីមលែរ ។ ពួកគេគឺជាមនុស្សដែលចូលចិត្តការកាប់សម្លាប់ ។ ភាសិតបារាំងមួយនិយាយថា ការឆ្ងាញ់ធ្វើឲ្យចង់ទទួលទាន៖ «អ្នកទទួលទានច្រើនកាលណា វារឹតធ្វើឲ្យអ្នកឆ្ងាញ់នឹងឈាមកាន់តែខ្លាំងឡើង» ។

*(កកន ៖ ស្តេចសីហនុគាត់មិនដែលបានដឹងអំពីកំហុសរបស់គាត់ម្តងណាឡើយ ។ គាត់គិតថា គាត់ហក់ទៅធ្វើជា «ស្តេចយៀកកុង» ហើយគៀងគរកងទ័ពយួនចូលមកឈ្លានពានស្រុកខ្លួនឯង គឺជាអំពើត្រឹមត្រូវ ។ គាត់គិតថា គាត់ទៅចូលដៃចូលជើងជាមួយពួកឃាតករខ្មែរក្រហម ប្រព្រឹត្តអំពើសម្លាប់រង្គាលមកលើប្រជារាស្ត្រខ្លួនឯង គឺជាអំពើត្រឹមត្រូវ ។ គាត់គិតថា ការឈ្លានពានរបស់យួនយកស្រុកធ្វើជាអាណានិគមរបស់វាកាល ពីថ្ងៃទី៧ មករា ១៩៧៩ គឺជាអំពើត្រឹមត្រូវ ។ យើងចង់ដឹងថា តើស្តេចសីហនុគាត់ឆ្ងាញ់នឹងឈាមរាស្ត្រខ្មែរ ឈាមព្រះសង្ឃខ្មែរណាស់ទៅឬ ដើម្បីឲ្យបានល្បីឈ្មោះដូចហូ-ជីមិញ ?) ។*

ប៉ូប៊ិយ ៖ ព្រះអង្គបានចូលដៃចូលជើងជាមួយខ្មែរក្រហមប្រឆាំងអាមេរិកាំងនិងលន់-នល់ ចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ សូម្បីព្រះអង្គនិរទេសគង់នៅទីក្រុងប៉េកាំងក្នុងរយៈពេលនោះ... ពិតប្រាកដណាស់ ព្រះអង្គមានគំនិតខ្លះអំពីផែនការរបស់ពួកគេ ។

នរោត្តម-សីហនុ ៖ ពេលរណសិរ្សប្រង្រួបបង្រួមដែលមានសីហនុជាប្រធាន ឈ្នះសង្គ្រាមនៅខែមេសាឆ្នាំ១៩៧៥, ខ្មែរក្រហមបាននិយាយប្រាប់ខ្ញុំថា មានតែមេដឹកនាំសាធារណរដ្ឋខ្មែរ៧នាក់ប៉ុណ្ណោះ ដែលត្រូវបាញ់ចោល ។ ដូច្នេះខ្ញុំក៏ប្រាប់ពួកគេវិញថា យល់ព្រម, ពីព្រោះខ្ញុំគិតថាយើងនឹងមានការសំរុះសំរួលគ្នាជាទូទៅ ។ នៅថ្ងៃទី១៧ខែមេសា ខ្ញុំរហូតដល់ទៅនិយាយប្រាប់ពួកអ្នកកាសែតនៅប៉េកាំងថា «អស់លោកមុខជាបានឃើញ... គឺនឹងមានការសំរុះសំរួលគ្នាជាទូទៅ» ។ នៅថ្ងៃទី១៧ខែមេសា

ខ្ញុំរហូតដល់ទៅនិយាយប្រាប់ពួកអ្នកកាសែតនៅប៉េកាំងថា «អស់លោកមុខជាបានឃើញ... គឺនឹងមានការសំរុះសំរួលគ្នាជាទូទៅ» ។ ហើយសេចក្ដីរាយការណ៍ដំបូងពីភ្នំពេញនិយាយថា ពួកខ្មែរក្រហមនិងពួកសាធារណរដ្ឋ, ពួកខ្មែរខៀវ, ជិះក្នុងឡានកាមីញុងជាមួយគ្នា, ច្រៀងសើចសប្បាយអ៊ឹងកង ។ ប៉ុន្តែប៉ុន្មានម៉ោងក្រោយមក អ្វីៗក៏ផ្លាស់ប្ដូរអស់ ។

*(កកន ៖នៅក្នុងសម្ភាសន៍ជាមួយលោក Alain Peyrefitte អតីតរដ្ឋមន្ត្រីការបរទេសបារាំងដែលបានចុះផ្សាយក្នុងទស្សនាវដ្ដី PARIS MATCH លេខ១៣៥៣ ថ្ងៃទី៣ ឧសភា ឆ្នាំ១៩៧៥ ស្ដេចសីហនុនិយាយថា ៖ គាត់មិនចូលក្រុងភ្នំពេញទេ បើគេមិនបណ្ដេញប្រជាពលរដ្ឋចេញអស់ជាមុនសិន ។ គាត់ថែមទាំងបញ្ជាឲ្យគេបាញ់សម្លាប់លោកលន់-នល់ និងប្រជាពលរដ្ឋខ្មែរដោយថ្នាក់ថ្នមថែមទៀតផង ។ តើទាំងនេះពុំមែនជាផែនការឬ ជាការគិតទុកជាមុនរបស់ស្ដេចសីហនុទេឬ ? ។ តើនេះពុំមែនជាផែនការ ដែលគាត់បានគិតទុកជាមុនកាលពី២០ឆ្នាំមុន ថាស្រុកខ្មែរនឹងផ្លាស់ប្ដូររបបទៅជារបបខ្មែរក្រហមទេឬ (ស្ដេចសីហនុបានសរសេរនៅក្នុងកាសែត «អ្នកជាតិនិយម» កាលពី១៨ ខែតុលា ឆ្នាំ១៩៥៥ ថា ៖ ម្ភៃឆ្នាំទៅមុខទៀត គឺនៅឆ្នាំ១៩៧៥ ស្រុកខ្មែរនឹងក្លាយទៅជារបបខ្មែរក្រហម) ។*

ប៉្លេប៊ិយ ៖ ពេលព្រះអង្គចូលទៅដល់ភ្នំពេញ តើព្រះអង្គមិនឃើញអ្វីកំពុងកើតឡើងទេឬ ?

នរោត្តម-សីហនុ ៖ ខ្ញុំបានឃើញការបង្ខំពលកម្ម ហើយនិងការសង្កត់សង្កិនសេរីភាពយ៉ាងដូច្នេះជាដើម ក៏ប៉ុន្តែខ្ញុំមិនបានឃើញទីលានពិឃាតទេ ។ ហើយនៅក្រោយការលាលែងពីតំណែងប្រធានរណសិរ្សបង្រួបបង្រួមនៅខែមេសា ១៩៧៦, ខ្មែរក្រហមប្រែក្លាយជាសត្រូវចំពោះខ្ញុំ ហើយពួកគេឃុំឃាំងខ្ញុំនិងប្រពន្ធខ្ញុំនៅក្នុងផ្ទះ ។ ពួកខ្មែរក្រហមចង់ឲ្យខ្ញុំស្ថិតនៅជាប្រមុខរដ្ឋ, ជាមេកំពូលរបស់ពួកគេ... ពីព្រោះនៅពីក្រោយឈ្មោះរបស់ខ្ញុំ, សូម្បីជាមួយរបបដ៏កំណាចក៏ដោយ ក៏ពួកគេអាចទទួលយល់ព្រមពីសហគមន៍អន្តរជាតិបានដែរ ។



ព្រះមហាវីរក្សត្រមានមោទនភាពក្រៃលែង តំណាងខ្មែរក្រហមនៅពេលមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឯកសណ្ឋានចិនកុម្មុយនិស្ត ។

*(កកន ៖ ពេលសារិន-ឆាក និងជួន-ប្រាសិទ្ធិទៅយាងស្ដេចសីហន ,នៅទីក្រុងប៉េកាំងចូលស្រុកខ្មែរ (ថ្ងៃទី១៨ កក្កដា ១៩៧៥) ស្ដេចសីហនុប្រកែកដាច់អហង្កា ។ ក្រោយមក ខៀវ-សំផនបានទៅពីងប៉ែន-នុតឲ្យជួយទៅតាមអង្វរករស្ដេចសីហនដល់វាំងព្យុងយ៉ាង (ថ្ងៃទី១៩ សីហា ១៩៧៥) ស្ដេចសីហនុយល់ព្រម ។ ស្ដេចសីហនុយល់ព្រមដោយសារមកពីប៉ែន-នុតក៏ដឹងក្រយៅរបស់ស្ដេចសីហនុ គឺបានសន្យាថា ខ្មែរក្រហមនឹងប្រគល់ដំណែងប្រមុខរដ្ឋអស់មួយជីវិតថ្វាយគាត់ ។ ស្ដេចសីហនុពុំបានហោះសំដៅទៅក្រុងភ្នំពេញភ្លាមទេ ។ គាត់ធ្វើលទៅចុះនៅហាណូយមួយអាទិត្យ (ថ្ងៃទី ២ កញ្ញា ១៩៧៥) ដើម្បីសុំការដឹងឮពីយួនជាមុនសិន ។*

*បើយោងតាមបទសម្ភាសន៍របស់គាត់ជាមួយលោក Alain Peyrefitte អតីតរដ្ឋមន្ត្រីការបរទេសបារាំង ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដី PARIS MATCH លេខ១៣៥៣ ថ្ងៃទី៣ ឧសភា ឆ្នាំ១៩៧៥ ៖ ស្ដេចសីហនុគាត់បានចេញបញ្ជាឲ្យពួកខ្មែរក្រហមបណ្ដេញប្រជាពលរដ្ឋខ្មែរចេញអស់ពីទីក្រុងទៅកាន់ទីជនបទ មុនពេលគាត់ចូលទៅដល់ ។ ម៉្លោះហើយស្អីក៏គាត់មិនបានឃើញដែរ កុំសូម្បីតែ «ទីលានពិឃាត» ពីព្រោះគាត់គឺជាអ្នកចេញបញ្ជាឲ្យបង្កើតទីលាននរកមួយនេះរួចទៅហើយ ។ គាត់រវល់អរកខិបកខុបជួបជាមួយពួកមេៗខ្មែរក្រហមដែលជារដ្ឋមន្ត្រីរបស់គាត់ ហើយស្រវឹងផប់ផលនឹងការសង់សឹក ។ ថ្ងៃទី២០ កញ្ញា ១៩៧៥ គាត់មានមោទនភាពក្រៃលែង ដោយចេញទៅធ្វើជាតំណាងខ្មែរក្រហមនៅក្នុង មហាសន្និបាតអង្គការសហប្រជាជាតិ ហើយនិងធ្វើដំណើរទស្សនកិច្ចប្រទេសចំនួនជាង១០ រួមទាំងប្រទេសបារាំងផង ។ តើស្ដេចសីហនុមិនពេញចិត្តនឹងខ្មែរក្រហមត្រង់កន្លែងណាទៅ ? ។*

*ស្ដេចសីហនុថា គាត់បានលាលែងពីតំណែង«ប្រធានរណសិរ្សបង្រួបបង្រួមកម្ពុជា» (FUNK) នាខែមេសាឆ្នាំ១៩៧៦ ។ តាមពិតពុំមែនយ៉ាងដូច្នោះទេ... ស្ដេចសីហនុគាត់លាលែងពីតំណែង «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» ពោលគឺប្រមុខរដ្ឋនៃរបបខ្មែរក្រហមទេតើ ។ ក្រោយពេលលាលែងបន្តិចមក គាត់និយាយថាខ្មែរក្រហមដាក់គុកគាត់នៅក្នុងវាំង ។ ចំណុចនេះវាគួរឲ្យចង់សើចថែមទៀត ពីព្រោះនៅពេលជាប់គុកនេះ គាត់មានពួកមេនុំមេនាងចុងភៅ មានអ្នកម្នាងនៅកំដរ មានកូនចៅនៅជិតខ្លួន (លើកលែងតែកូនជាមួយស្នំផ្សេងៗ ដែលគាត់ទុកឲ្យខ្មែរក្រហមសម្លាប់) ហើយនិងមានចុងភៅសំរាប់ដាំស្ងួថ្វាយថែមទៀតផង ។*

*យើងបានសង្កេតឃើញថា នៅរៀងរាល់ពេលដែលស្ដេចសីហនុរួច ចេញពីទ្រុងរបស់ខ្មែរក្រហម គាត់មិនដែលធ្វើអ្វីប្រឆាំងនឹងនយោបាយរបស់ខ្មែរក្រហមទេ ។ ផ្ទុយទៅវិញ គាត់ត្រឡប់ទៅជាមានមោទនភាពធ្វើជាតំណាងឲ្យក្រុមខ្មែរក្រហម រួចហើយវិលទៅចូលរួមដៃរួមជើងជាមួយខ្មែរក្រហមវិញដដែល រហូតមកទល់សព្វថ្ងៃនេះ) ។*

(នៅមានត)